អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៦ ចេញផ្សាយ ខែមិថុនា ឆ្នាំ២០២២

## តើសវនកម្មអនុលោមភាពជាអ្វី?

### និយមន័យ

**អនុលោមភាព**សំដៅដល់សកម្មភាពដែលប្រកាន់ខ្ជាប់នូវ ឬតម្រូវតាម ឬធ្វើឱ្យស្របទៅតាមច្បាប់បទប្បញ្ញត្តិនានា គោលនយោបាយ ស្តង់ដាររបស់ស្ថាប័ន គោលការណ៍អភិបាលកិច្ច ស្តង់ដាសីលធម៌ ឧត្តមានុវត្ត និងនីតិវិធីផ្ទៃក្នុងដែលស្របទៅតាមសកម្មភាពការងារ ឬកិច្ចដំណើរការរបស់ស្ថាប័ន។

**សវនកម្ម** សំដៅការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យ របាយការណ៍ កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់ស្ថាប័នចំពោះគោលបំណងជាក់លាក់ណាមួយ។

**សវនកម្មអនុលោមភាព** ជាការត្រួតពិនិត្យ និងវាយតម្លៃលើភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា ឬជាការពិនិត្យឡើងវិញ និងវាយតម្លៃដោយឯករាជ្យ ថាតើសកម្មភាព ឬការបំពេញការងាររបស់ស្ថាប័នត្រូវបានអនុវត្ត ដោយស្របតាមបទប្បញ្ញត្តិជាធរមាន (រដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយ កិច្ចព្រមព្រៀង កិច្ចសន្យា និងក្រមអនុវត្ត- ល-) ដែរ ឬទេ។

### គោលបំណង

**គោលបំណងនៃសវនកម្មអនុលោមភាពគឺ** ដើម្បីស្វែងរកនូវព័ត៌មានថាតើសវនដ្ឋាន ឬស្ថាប័នរងសវនកម្មទាំងនោះបានធ្វើកិច្ចការងារឆ្លើយតប ឬស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែរឬទេ។ ជាពិសេសជាការបន្ថែមនូវប្រសិទ្ធភាព គុណភាព និងគុណតម្លៃដល់សវនដ្ឋាន ឬស្ថាប័នក្នុងការបំពេញការងាររបស់ខ្លួនទៅតាមការនិយាមដែលបានកំណត់។

### ដំណើរការសវនកម្មអនុលោមភាព

**ការធ្វើផែនការសវនកម្មអនុលោមភាព÷** មុននឹងធ្វើសវនកម្មបានលុះត្រាតែមានការកំណត់អំពីផែនការសវនកម្មឱ្យបានច្បាស់លាស់ និងត្រូវរៀបចំប្រកបដោយគុណភាពខ្ពស់ ដែលមានលក្ខណៈសន្សំសំចៃ ប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីអនុវត្តសវនកម្មអនុលោមភាពនេះឱ្យបានជោគជ័យក្នុងបំណងតាមរកកំហុសអចេតនា ភាពមិនប្រក្រតី និងទង្វើមិនស្របច្បាប់នានាជាសារវ័ន្ត។

**ការធ្វើសវនកម្មអនុលោមភាព÷** ការចុះពិនិត្យ និងផ្ទៀងផ្ទាត់លើសកម្មភាពរបស់សវនដ្ឋាន ដោយផ្អែកលើផែនការសវនកម្មដែលបានកំណត់ជាស្រេច។ ក្នុងនោះផងដែលការចុះធ្វើសវនកម្មរួមមាន ការប្រមូលយកភស្តុតាង ការចងក្រងឯកសារ ការសួរសំណួរពាក់ព័ន្ធ របកគំហើញអំពើមិនស្របច្បាប់ និងការវាយតម្លៃទៅលើទិន្នន័យទាំងអស់នោះ។

**របាយការណ៍ និងការតាមដានអនុសាសន៍សវនកម្មអនុលោមភាព÷** ក្រោយពេលការចុះធ្វើសវនកម្ម ការរៀបចំរបាយការណ៍ ជាផ្នែកមួយដែលចាំបាច់ឆ្លើយតបទៅលទ្ធផលនៃសវនកម្ម និងពាក់ព័ន្ធនឹងការរាយការណ៍អំពីគម្លាត និងការរំលោភបំពានច្បាប់។ ជាមួយគ្នាផងដែរ ការកំណត់អំពីការចាត់វិធានការកែលម្អអាចត្រូវបានអនុវត្ត និងដាក់ឱ្យមានការទទួលខុស-ត្រូវចំពោះសកម្មភាពរបស់សវនដ្ឋាន ជាមួយការតាមដានលើការអនុវត្តលើវិធានការនេះផងដែរ។

### អត្ថប្រយោជន៍

**សវនកម្មអនុលោមភាពបានផ្តល់នូវការកែលម្អទៅរកភាពល្អប្រសើរ និងផលប្រយោជន៍ដូចជា÷**

- កំណត់ពីស្ថានភាពនៃអនុលោមភាព
- កំណត់ចំណុចខ្វះខាតនៃការអនុលោមតាមច្បាប់ដែលបានមើលរំលង
- គ្រប់គ្រងហានិភ័យបានល្អក្នុងការអនុវត្តសវនកម្មអនុ-លោមភាពដែលមានប្រសិទ្ធភាពខ្ពស់
- ធានាការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានា
- បង្កើនភាពប្រសើរនូវគុណភាព និងគុណតម្លៃប្រកបដោយគណនេយ្យភាព តម្លាភាព អភិបាលកិច្ចល្អរបស់ស្ថាប័នរងសវនកម្ម- ល-។

**អត្ថបទ÷** លោកស្រី **ឆាង សិទ្ធត**

**ឯកសារយោង÷**

*១- គោលការណ៍ណែនាំស្តីពីសវនកម្មលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសវនកម្មជាតិឆ្នាំ២០១៩*
*២- មូលដ្ឋានគ្រឹះនៃគោលការណ៍នៃសវនកម្មវិស័យសាធារណៈ ISSAI 100*
*៣- គោលការណ៍នៃការធ្វើសវនកម្មអនុលោមភាព ISSAI 400។*



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។